**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ : ១៦/១៩**

**សេចក្តីជូនដំណឹង**
**ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ ការងារបំពាក់គ្រឿងស្ទូតភ្ជាប់បណ្តាញអគ្គិសនីមេ (ដំណាក់កាលទី២) ចូលអាកាសយានដ្ឋានកោះកុង និងជួសជុលបណ្តាញ ហើយបំពាក់គ្រឿងអគ្គិសនីនៅស្ថានីយ៍អ្នកដំណើរ**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារបំពាក់គ្រឿងស្ទូតភ្ជាប់បណ្តាញអគ្គិសនីមេ(ដំណាក់កាលទី២) ចូលអាកាសយានដ្ឋានកោះកុង និងជួសជុលបណ្តាញ ហើយបំពាក់គ្រឿងអគ្គិសនីនៅស្ថានីយ៍អ្នកដំណើរ។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានអាសយដ្ឋានលេខៈ ៤៤, មហាវិថី សហព័ន្ធរុស្ស៊ី,ភូមិ តាងួន,សង្កាត់ កាកាប,ខណ្ឌ ពោធិ៍សែនជ័យ, រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...០៨.....ខែ....វិច្ឆិកា......ឆ្នាំ ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ ០២៣ ៨៩០ ១៦៥)។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី..២៥..ខែ.វិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោង:.០៩.ម៉ោង.ព្រឹក...។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង: .០៩.ម៉ោងព្រឹក..ថ្ងៃទី...២៥....ខែ...វិច្ឆិកា......ឆ្នាំ ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ.ព្រហស្បតិ៍ ១០ កើត.ខែ.....កត្តិក.........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.០៧....ខែ..វិច្ឆិកា....ឆ្នាំ ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

<u>ចម្លងជូន៖</u>
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសា-កាលប្បវត្តិ